អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា ៖**

- វិបត្តិកូវីដ១៩កំពុងតែអង្រួនទំនុកចិត្តពាណិជ្ជកម្មនៅកម្ពុជា
- ប្រទេសកម្ពុជាកំពុងរៀបចំខ្លួន ដើម្បីចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសកាណាដា
- តារាងទី១៖ ការព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ២០២១ និង ២០២២
- តារាងទី២៖ ការចំណាយលើអត្ថប្រយោជន៍សង្គម នៅត្រីមាសទី១ ឆ្នាំ២០២១
- ការនាំចេញរបស់វៀតណាមក្នុងរយៈពេល៥ខែដំបូងឆ្នាំនេះកើនឡើង ៣០,៧%
- ទិន្នផលឧស្សាហកម្មរបស់ជប៉ុនបានកើនឡើងដោយសារតម្រូវការទំនិញមូលធននៅក្នុងខែមេសា
- ការប្រៀបធៀបកំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់ (GDP per capita) នៅក្នុងបណ្តាប្រទេសអាស៊ាន (២០១៩-២០២២)
- OECD លើកឡើងថា សេដ្ឋកិច្ចសកល នឹងវិលទៅរកទំហំមុនវិបត្តិ នៅត្រឹមឆ្នាំ២០២២
- អតិផរណាអាមេរិក ត្រូវបានរំពឹងថានឹងមានអត្រា ចន្លោះ ២,៥% ទៅ ៣% នៅឆ្នាំនេះ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## វិបត្តិកូវីដ-១៩ កំពុងតែអង្រួនទំនុកចិត្តពាណិជ្ជកម្មនៅកម្ពុជា



*រូបថត៖ Hong Menea, Phnom Penh Post ២០២១*

យោងតាមការស្ទង់មតិទំនុកចិត្តពាណិជ្ជកម្ម ដែលបានធ្វើឡើងអំលុងចុងឆ្នាំ២០២០ និងដើមឆ្នាំ២០២១ របស់សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជាបានបង្ហាញថា ការរីករាលដាលជំងឺកូវីដ១៩ និងភាពមិនច្បាស់លាស់របស់សេដ្ឋកិច្ច បានធ្វើឱ្យសន្ទស្សន៍ទំនុកចិត្តពាណិជ្ជកម្មនៅកម្ពុជាធ្លាក់ចុះពី ៥២,៩% នៅក្នុងឆ្នាំ២០១៩ មកនៅត្រឹម ៤៦,១% ក្នុងឆ្នាំ២០២១ នេះ។

ការស្ទង់មតិនេះក៏បានបង្ហាញផងដែរថា ការយល់ឃើញចំពោះភាពងាយស្រួលរបស់ពាណិជ្ជករចំពោះការធ្វើជំនួញនៅកម្ពុជា បានធ្លាក់ចុះពី ១៨% នៅក្នុងឆ្នាំ២០១៩ មកនៅត្រឹម១២% នៅក្នុងឆ្នាំ២០២១។ ជាក់ស្តែងក្នុងចំណោមអាជីវកម្មចូលរួមការស្ទង់មតិសរុប ៣៥០ អាជីវកម្មចំនួន៧៧% រកចំណូលបានទាបជាងគោលដៅដែលរំពឹងទុកក្នុងអំលុងពេល១២ខែចុងក្រោយ ខណៈដែលចំនួនអាជីវកម្មដែលសម្រេចតាមគោលដៅធ្លាក់ចុះពី ៣២%ក្នុងឆ្នាំ២០១៩ មកនៅត្រឹម២១% នៅក្នុងឆ្នាំ២០២១។ ជារួមអ្នកដែលយល់ឃើញថា ការធ្វើអាជីវកម្មនៅកម្ពុជាងាយស្រួលជាងមុនមានចំនួនត្រឹមតែ ២៧% ប៉ុណ្ណោះ ដោយសារតែពួកគេមានអារម្មណ៍អវិជ្ជមានចំពោះការិយាធិបតេយ្យ ការយកកម្រៃក្រៅផ្លូវការ ការប្រកួតប្រជែងមិនស្មោះត្រង់ និងការយកពន្ធលំអៀងជាដើម បើទោះជាមានការកែលម្អច្រើនក្តី។

តាមការស្ទង់មតិដដែលនេះបានបង្ហាញថា ៥៦%នៃពាណិជ្ជករបានព្យាករណ៍ថាពាណិជ្ជកម្មរបស់ពួកគេនឹងមានការកើនឡើងវិញក្នុងអំលុងពេល១២ខែខាងមុខនេះ ដែលការយល់ឃើញបែបសុទិដ្ឋិនិយមនេះមានការធ្លាក់ចុះពីចំនួន ៧២% នៅក្នុងឆ្នាំ២០១៩។ ទោះយ៉ាងណានេះនៅតែជាសូចនាករវិជ្ជមានមួយ ក្នុងអំលុងពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងតែប្រឈមនឹងវិបត្តិកូវីដ១៩។

ម្យ៉ាងវិញទៀត ៩០% នៃអ្នកដែលបានឆ្លើយតបចំពោះការស្ទង់មតិនេះយល់ឃើញថា អាជីវកម្មរបស់ពួកគេរងផលប៉ះពាល់ពីកូវីដ១៩ ក្នុងកម្រិតមធ្យម និងអាជីវករមួយភាគបីទៀតយល់ថា អាជីវកម្មរបស់ពួកគេទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ។ ដោយឡែក ១០% នៃអាជីវករបានឆ្លើយថា អាជីវកម្មរបស់ពួកគេមិនទទួលរងផល

ប៉ះពាល់អ្វីឡើយ ចំណែកឯ ៤%ទៀតដែលប្រកបអាជីវកម្ម តាមប្រព័ន្ធអេឡិចត្រូនិកឆ្លើយថា អាជីវកម្មពួកគេមានភាពល្អប្រសើរជាងពីមុន ពេលគឺ ទទួលបានផលវិជ្ជមាន។

ទន្ទឹមនឹងនេះផងដែរ លោក អ៊ិន ចាន់នី នាយកប្រតិបត្តិធនាគារអេស៊ីលីដាបានលើកឡើងថា៖ “*បរិយាកាសអាជីវកម្មនៅកម្ពុជានៅតែល្អ និងនៅតែមានអំណោយផល បើទោះបីជាការរីករាលដាលជំងឺកូវីដ១៩ នៅតែបន្តកើតមានក្តី*”។ ម្យ៉ាងវិញទៀត ប្រសិនបើប្រៀបធៀបកម្រិតនៃការប្រកួតប្រជែងនៅក្នុងតំបន់ដែលបានធ្វើឡើងក្នុងការស្ទង់មតិនេះ ការប្រកួតប្រជែងទីផ្សាររបស់កម្ពុជានៅក្នុងតំបន់មានភាពវិជ្ជមានជាងឆ្នាំ២០១៩ គឺកើនពី ៣៨% ក្នុងឆ្នាំ២០១៩ ដល់ ៤៨% នៅក្នុងឆ្នាំ ២០២១។

ដោយឡែក ពាណិជ្ជករចំនួន ៦៧% បាននិយាយថា ការដក EBA របស់សហគមន៍អឺរ៉ុបមិនធ្វើឱ្យប៉ះពាល់ដល់ជំនួញរបស់ពួកគេនោះទេ។ ខណៈដែល ៣០% ទៀតនិយាយថា ពួកគេមានអារម្មណ៍ថា ការដក EBA បានជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្មរបស់ពួកគេ។ អគ្គលេខាធិការសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានលើកឡើងថា ព្រះរាជាណាចក្រកម្ពុជា នៅតែជាកន្លែងដែលគួរឱ្យចាប់អារម្មណ៍ចំពោះការវិនិយោគ។

គួររំលឹកថា កាលពីឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាបានធ្លាក់ចុះខ្លាំងបំផុត នៅក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ។ នៅក្នុងនោះវិស័យទេសចរណ៍ សំណង់ និងកម្មន្តសាលរងផលប៉ះពាល់យ៉ាងខ្លាំង។ ទោះយ៉ាងណា ការស្ទង់មតិលើសមាជិករបស់សភាពាណិជ្ជកម្មអឺរ៉ុបដែលមានអាជីវកម្មនៅក្នុងវិស័យនានា ដែលទទួលរងផលប៉ះពាល់ខ្លាំងពីវិបត្តិកូវីដ ដូចជា វិស័យសេវាកម្ម អប់រំ ទេសចរណ៍ និងបដិសណ្ឋារកិច្ចបានបង្ហាញថា ការធ្លាក់ចុះនៃទំនុកចិត្តក្នុងការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាហាក់មានភាពធូរស្រាលជាងការរំពឹងទុក៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ Phnom Penh Post ចេញផ្សាយថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១*

## ប្រទេសកម្ពុជាកំពុងរៀបចំខ្លួន ដើម្បីចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងប្រទេសកាណាដា



*ប្រភព៖ postkhmer, 2021*

សេចក្តីព្រាងឯកសារគ្របខណ្ឌ សម្រាប់ការចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា ត្រូវបានកិច្ចប្រជុំអន្តរក្រសួងលើកយកមកប្រជុំតាមប្រព័ន្ធអនឡាញកាលពីថ្ងៃទី២៧ ខែឧសភា កន្លងទៅនេះ ដើម្បីប្រមូលធាតុចូលគ្រប់ផ្នែកពាក់ព័ន្ធ ក្នុងជំពូកស្តីពីបរិស្ថាន។

ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថានបាន លើកឡើងថា ការផ្តល់ធាតុចូលរបស់ផ្នែកពាក់ព័ន្ធនេះ គឺធ្វើឡើងក្នុងគោលបំណងធានាសម្រេចបាននូវជោគជ័យរបស់កម្ពុជាក្នុងការធ្វើសមាហរណកម្មថ្នាក់តំបន់ និងជំរុញឱ្យពាណិជ្ជកម្មរវាងប្រទេសកាណាដាជាមួយប្រទេសក្នុងតំបន់រួមទាំងកម្ពុជា មានទំហំកាន់តែធំឡើងៗ។

យោងតាម លោក ពេជ ឫទ្ធី រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មបានលើកឡើងថាៈ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា គឺមានសារៈសំខាន់ណាស់ក្នុងការជួយជំរុញការធ្វើពាណិជ្ជកម្មរវាងប្រទេសកាណាដាជាមួយប្រទេសក្នុងតំបន់អាស៊ានរួមទាំងកម្ពុជា ឱ្យមានទំហំកាន់តែធំ ព្រោះកាណាដាជាប្រទេសធំ និងមានសេដ្ឋកិច្ចរីកចម្រើន។ ទោះបីជាវិបត្តិនៃការឆ្លងរាលដាលជំងឺកូវីដ-១៩បានធ្វើឱ្យប៉ះពាល់ ដល់ការធ្វើពាណិជ្ជកម្មជាអន្តរជាតិនៅលើពិភពលោក ក៏ប្រទេសកាណាដានៅតែឈរនៅលេខរៀងទី៨កាលពីឆ្នាំ ២០២០ ក្នុងនាមជាប្រទេសមានទំនាក់ទំនងពាណិជ្ជកម្មធំជាងគេជាមួយកម្ពុជា។

តាមរបាយការណ៍ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថា ក្នុងឆ្នាំ ២០២០ ពាណិជ្ជកម្មទ្វេភាគី កម្ពុជា-កាណាដា មានតម្លៃសរុបចំនួន ៨០០,៤ លានដុល្លារ បានធ្លាក់ចុះ ១៦,៤៤% បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ ក្នុងនោះការនាំចេញទំនិញពីកម្ពុជាមានតម្លៃ៧៤៥,០៤លានដុល្លារ ធ្លាក់ចុះ ១០,៩៥ % និង ការនាំចូលទំនិញពី កាណាដា មានតម្លៃ ៥៥,៣៦ លានដុល្លារ ធ្លាក់ចុះ ៥៤,៣១%៕

*ដោយ សេន ចន្ទ*

*ប្រភពៈ postkhmer.com ចេញផ្សាយថ្ងៃទី២៩ខែឧសភាឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍ៈ

## តារាងទី១ៈ ការព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០២១ និង ២០២២

យោងតាមការព្យាករណ៍ របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)ដែលចេញផ្សាយនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២១ បង្ហាញថា ៖ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជានឹងកើនឡើងប្រមាណ ៤,០% នៅឆ្នាំនេះ និង ៥,៥% ក្នុងឆ្នាំ២០២២ ដោយសារតែការងើបឡើងវិញនៃសេដ្ឋកិច្ចនៅក្នុងប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗ ដែលជួយជំរុញតម្រូវការនៃការនាំចេញរបស់ប្រទេសកម្ពុជា ។

ទន្ទឹមនឹងនោះដែរ ផលិតកម្មឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើង៧,១%នៅឆ្នាំ២០២១ និង៧,០% នៅឆ្នាំ២០២២ ដោយសារការស្ទុះងើបឡើងវិញនៃវិស័យកាត់ដេរ សម្លៀកបំពាក់ ស្បែកជើង និងទំនិញសម្រាប់ធ្វើដំណើរ ក៏ដូចជាការរីកចម្រើនក្នុងផលិតកម្មធុនស្រាលផ្សេងទៀត ដូចជាអេឡិចត្រូនិច និងកង់។ វិស័យកសិកម្មក៏ត្រូវបានគេរំពឹងថា នឹងកើនឡើងប្រហែល ១,៣% ក្នុងឆ្នាំ២០២១ និង១,២% ក្នុងឆ្នាំ២០២២ ដែលគាំទ្រដោយផលិតកម្មដំណាំដែលមានកំណើនខ្ពស់ ការកើនឡើងនូវវារីវប្បកម្ម និងការកើនឡើងនូវការនាំចេញកសិកម្មទៅកាន់ប្រទេសចិន។

ដោយឡែក វិស័យសេវាកម្មនឹងស្ទុះងើបឡើងវិញយឺតៗ ដោយមានកំណើនប្រមាណជា៣,៣% ក្នុងឆ្នាំ២០២១ និង ៦,២% ក្នុងឆ្នាំ ២០២២ ផងដែរ។

*ដោយ មិត្ត ចន្ទី*




*ប្រភព៖ ធនាគារអភិវឌ្ឍន៍អាស៊ីADB)* (២០២១-២០២២៖ ការព្យាករណ៍)

## តារាងទី២៖ ការចំណាយលើអត្ថប្រយោជន៍សង្គម នៅត្រីមាសទី១ ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅត្រីមាសទី១ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ បានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន៣៥៤,៦៣ប៊ីលានរៀល ដែលមានកំណើនប្រមាណជា ០,៥% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

កំណើននៃការចំណាយនេះ ដោយសារតែរាជរដ្ឋាភិបាលបានប្រើប្រាស់ថវិកា ដើម្បីជួយដោះស្រាយនូវផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ទៅលើផ្នែកសុខាភិបាល សង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។

ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន២៥០,៣០ប៊ីលានរៀល នៅត្រីមាសទី១ ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ២,៩% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន។

ស្របពេលដូចគ្នានេះដែរ ការចំណាយលើជំនួយដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ៨៩,៧៥ប៊ីលានរៀល នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលមានការកើនឡើងប្រមាណជា ០,៤%។

ទោះបីយ៉ាងណាក៏ដោយ ការចំណាយលើការឧបត្ថម្ភអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ មានទំហំទឹកប្រាក់១៤,៥៨៣ប៊ីលានរៀល នៅក្នុងត្រីមាសទី១ឆ្នាំ២០២១ ដែលមានការធ្លាក់ចុះ ២៨,៤% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មិនមានទេ នៅក្នុងត្រីមាសទី១ ឆ្នាំ២០២១នេះ៕

*ដោយ មិត្ត ចន្នី*

| ការចំណាយឆ្នាំ២០២១ (គិតជាប៊ីលានរៀល) | ២០២០ | ២០២១ | កំណើន/ថយ(%) |
|---|---|---|---|
| | ត្រីមាសទី១ | ត្រីមាសទី១ | |
| អត្ថប្រយោជន៍សង្គម | 353.01 | 354.63 | 0.5% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 243.28 | 250.30 | 2.9% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 89.37 | 89.75 | 0.4% |
| ឧបត្ថម្ភអង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | 20.36 | 14.58 | -28.4% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | 0.0% |

*ប្រភព៖តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំខែធ្នូ ឆ្នាំ២០២០ និង ខែមីនា ឆ្នាំ២០២១*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការនាំចេញរបស់វៀតណាម ក្នុងរយៈពេល៥ខែដំបូងឆ្នាំ២០២១នេះ កើនឡើង ៣០,៧%



*ប្រភព៖ [Viet Nam News 2021, រូបភាព៖Vu Sinh]*

យោងតាមការិយាល័យស្ថិតិទូទៅវៀតណាម(GSO) បានឱ្យដឹងថាការនាំចេញទំនិញ ក្នុងរយៈពេល ៥ ខែដំបូងនៃឆ្នាំ ២០២១ មានតម្លៃ ១៣០,៩៤ ប៊ីលានដុល្លារ កើនឡើង ៣០,៧ % ដែល រួមចំណែកដោយវិស័យក្នុងស្រុក និងវិស័យវិនិយោគផ្ទាល់ពីបរទេស (FDI) (រួមបញ្ចូលទាំងប្រេងឆៅ) បានកើនឡើង ១៦,៦% និង ៣៦,៣ % រៀងគ្នាធៀបនឹងឆ្នាំកន្លងទៅ។

ទន្ទឹមនឹងនេះ ការនាំចេញទំនិញឧស្សាហកម្មធុនធ្ងន់ និងរ៉ែ បានកើនឡើង ៣៣% ឧស្សាហកម្ម និងសិប្បកម្មធុនស្រាលបានកើនឡើង ៣៣% ផលិតផលកសិកម្ម និងព្រៃឈើកើនឡើង ១៣,៥% និងផលិតផល ជលផលកើនឡើង១២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំកន្លងទៅ។

ទីផ្សារនាំចេញធំបំផុតរបស់ប្រទេសវៀតណាម គឺសហរដ្ឋអាមេរិកឈរលេខរៀងទី១ ប្រទេសចិននៅលេខរៀងទី២ ដែលតម្លៃនាំចេញមានកំណើន ៤៩,៨% និង២៦% រៀងគ្នាធៀបនឹងឆ្នាំមុន។ សហភាពអ៊ឺរ៉ុប និងអាស៊ានមានលេខរៀងបន្ទាប់ និងមានកំណើនពីមួយឆ្នាំទៅមួយឆ្នាំ គឺ ២០,៨% និង២៣,៧%រៀងគ្នា។

នៅក្នុងខែឧសភា ការនាំចេញរបស់វៀតណាមមានតម្លៃ ២៦ ប៊ីលានដុល្លារបានធ្លាក់ចុះ ២,១ %ធៀបនឹងខែមុន និងកើនឡើង ៣៥,៦%ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ចំណែកឯការនាំចូលរបស់ប្រទេសវៀតណាម ក្នុងរយៈពេល៥ ខែ (មករា-ឧសភា) ក្នុងឆ្នាំ២០២១នេះ មានចំនួន ១៣១,៣១ ប៊ីលានដុល្លារដែលមានកំណើនប្រចាំឆ្នាំ ៣៦,៤% ហើយប្រទេសចិនគឺជាទីផ្សារនាំចូលធំបំផុតរបស់វៀតណាម៕*ដោយមុំ ចិន្តា*

*ប្រភព៖* Viet Nam News 2021 *ចេញផ្សាយថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០២១*

### ទិន្នផលឧស្សាហកម្មរបស់ជប៉ុនបានកើនឡើងក្នុង ខែមេសា ដោយសារមានតម្រូវការទំនិញមូលធន



*ប្រភព៖ [Reuters 2021, រូបភាព៖ Toru Hanai]*

ទិន្នផលឧស្សាហកម្មរបស់ជប៉ុន បានកើនឡើងក្នុងខែមេសា ដោយសារការស្ទុះងើបឡើងនៃតម្រូវការទំនិញជាពិសេសនៅទីផ្សារបរទេស។

ប្រទេសជប៉ុនបានរំពឹងថា សេដ្ឋកិច្ចរបស់ខ្លួននឹងកើនឡើងនៅក្នុងត្រីមាសទី២ ក្នុងល្បឿនយឺត នេះបើយោងតាមការព្យាករណ៍ពីពេលកន្លងទៅ។ ការកើនឡើងនេះបានរួមចំណែកដោយវិធានការណ៍សង្គ្រោះបន្ទាន់បន្ថែមរបស់រដ្ឋាភិបាល ដើម្បីបញ្ឈប់ការកើនឡើងនៃជំងឺឆ្លងកូវីដ-១៩ នៅទីក្រុង តូក្យូ និងតំបន់សំខាន់ៗផ្សេងទៀត។

យោងតាមទិន្នន័យផ្លូវការបានបង្ហាញថា ទិន្នផលរបស់រោងចក្របានកើនឡើង ២,៥%ក្នុងខែមេសាធៀបនឹងខែមុន ដោយសារការកើនឡើង នៃផលិតកម្មម៉ាស៊ីនទូទៅ(General-purpose) និងម៉ាស៊ីនអេឡិចត្រូនិចដែលបានប៉ះប៉ូវដល់ការធ្លាក់ចុះផលិតកម្មរថយន្តដោយសារតែមានបញ្ហានៃការផ្គត់ផ្គង់។

បន្ថែមពីនេះ ការនាំចេញទំនិញមូលធនដូចជា គ្រឿងម៉ាស៊ីនផលិតកម្មទៅកាន់សហរដ្ឋអាមេរិក និងចិនបានកើនឡើងដែលបង្ហាញថាតម្រូវការទីផ្សារបរទេស កំពុងមានការកើនឡើង ខណៈពេលដែលមានការងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក។

នៅក្នុងខែមេសា ការលក់រាយបានកើនឡើង១២% ធៀបនឹងឆ្នាំមុន ដោយការកើនឡើងភាគច្រើនបណ្តាលមកពីតម្រូវការទំនិញប្រើប្រាស់ទូទៅ និងសម្លៀកបំពាក់។

ទោះជាយ៉ាងណាការលក់រាយបានធ្លាក់ចុះ ៤,៥% នៅលើមូលដ្ឋាននៃការកែតម្រូវតាមរដូវកាលធៀបនឹងខែមុន ដោយសារអ្នកប្រើប្រាស់បានចូលរួមក្នុងវិធានថ្មីរបស់រដ្ឋាភិបាលដើម្បីបញ្ឈប់ការឆ្លងរាលដាលនៃជំងឺ កូវីដ-១៩។ *ដោយ មុំ ចិន្តា*

*ប្រភព៖ Reuters ចេញផ្សាយថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០២១*

## ការប្រៀបធៀបកំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់ (GDP per capita) នៅក្នុងបណ្តាប្រទេសអាស៊ាន (២០១៩-២០២២)




*ប្រភព៖ ទិន្នន័យ ADB: Growth rate of GDP per capita*

រូបខាងលើបង្ហាញពីកំណើន ផ.ស.ស សម្រាប់មនុស្សម្នាក់ (GDP per capita) របស់បណ្តាប្រទេសដែលជាសមាជិកអាស៊ានចាប់ពីឆ្នាំ២០១៩ រហូតដល់ឆ្នាំ២០២២ គិតជាភាគរយក្នុងមួយឆ្នាំ។ នៅក្នុងរូបនេះ បង្គោលពណ៌ខៀវដំណាងឱ្យ GDP per capita ឆ្នាំ២០១៩ បង្គោលពណ៌ទឹកក្រូចដំណាងឱ្យ GDP per capita ឆ្នាំ ២០២០ បង្គោលពណ៌ប្រផេះតំណាងឱ្យ GDP per capita ឆ្នាំ២០២១ និងបង្គោលពណ៌លឿងដំណាងឱ្យ GDP per capita ឆ្នាំ២០២២។

យោងតាមរូបខាងលើ នៅក្នុងឆ្នាំ២០១៩ កំណើន GDP per capita របស់ប្រទេសព្រុយណេស្មើនឹងសូន្យ។ រីឯអត្រាកំណើន GDP per capita របស់ប្រទេសសឹង្ហបូរី

នៅក្នុងឆ្នាំ២០១៩ មានកម្រិតទាបស្មើនឹង ០,១៩% ខណៈដែលកំណើន GDP per capita របស់មីយ៉ាន់ម៉ា នៅក្នុងឆ្នាំ២០១៩ ខ្ពស់ជាងគេស្មើនឹង ៥,៨១%។ បន្ទាប់មកប្រទេសកម្ពុជា ៥,៥៨% វៀតណាម ៥,០០% ហ្វីលីពីន ៤,៦០% ឥណ្ឌូនេស៊ី ៣,៩៤% ម៉ាឡេស៊ី ៣,៨៥% និងថៃ ២,០៤%។

ដោយឡែកនៅក្នុងឆ្នាំ២០២០ បន្ទាប់ពីសេដ្ឋកិច្ចទទួលរងផលប៉ះពាល់ពីវិបត្តិកូវីដ១៩ កំណើន GDP per capita របស់ប្រទេសទាំង១០ នៅអាស៊ានធ្លាក់ចុះទាំងអស់ ដែលនៅក្នុងចំណោមនោះកំណើន GDP per capita របស់ហ្វីលីពីនធ្លាក់ចុះខ្លាំងជាងគេ ក្នុងអត្រាអវិជ្ជមានដល់ទៅ ១០,៨១%។ គួរកត់សំគាល់ថា នៅក្នុងឆ្នាំ ២០២០ មានតែកំណើន GDP per capita របស់ប្រទេសមីយ៉ាន់ វៀតណាម និងព្រុយណេប៉ុណ្ណោះ ដែលមានកំណើនវិជ្ជមានក្នុងអត្រា ២,៣៦%, ១,៧៥% និង០,២៣% រៀងគ្នា។

ផ្ទុយទៅវិញ យោងតាមការព្យាករណ៍របស់ ADB នៅក្នុងឆ្នាំ២០២១ នេះ កំណើន GDP per capita របស់ពលរដ្ឋមីយ៉ាន់ម៉ា ធ្លាក់ចុះយ៉ាងខ្លាំងផ្ទុយពីឆ្នាំ២០២០ ក្នុងអត្រា ១០,៦០%។ ខណៈដែលប្រទេសប្រាំបួនផ្សេងទៀត មានអត្រាកំណើនល្អប្រសើរ និងវិជ្ជមានទាំងអស់។ នៅក្នុងនោះកំណើន GDP per capita របស់ពលរដ្ឋសឹង្ហបុរី ឈរនៅលំដាប់លេខរៀងទី១ ជាមួយនឹងអត្រាកំណើន ៥,៧៤%។ ទន្ទឹមនឹងនេះ ការព្យាករណ៍កំណើន GDP per capita សម្រាប់ឆ្នាំ២០២២ បានបង្ហាញថា អត្រាកំណើន GDP per capita ប្រទេសអាស៊ាន មានសញ្ញាណងើបឡើងវិញ និងមានអត្រាកំណើនវិជ្ជមានទាំងអស់ (លើកលែងប្រទេសមីយ៉ាន់ម៉ា) ដែលនៅក្នុងនោះ ប្រទេសវៀតណាម មានកំណើនខ្ពស់ជាងគេ និងតាមពីក្រោយដោយប្រទេសម៉ាឡេស៊ី និងហ្វីលីពីន។ គួរបញ្ជាក់ផងដែរថា យោងតាមទិន្នន័យរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ខាងលើ ពុំមានតួលេខកំណើន GDP per capita របស់ប្រទេសមីយ៉ាន់ម៉ា នៅក្នុងឆ្នាំ២០២២ ទេ៕

*ដោយ វង្ស ច័ន្ទស្មើដារ៉ា*

## សេដ្ឋកិច្ចសកល

### OECD លើកឡើងថា សេដ្ឋកិច្ចសកលនឹងវិលទៅរកទំហំមុនវិបត្តិ នៅត្រឹមឆ្នាំ២០២២



*ប្រភព៖ Bloomberg ២០២១*

យោងតាមការព្យាករណ៍ថ្មីៗរបស់ OECD បង្ហាញថា សេដ្ឋកិច្ចសកល នៅឆ្នាំ២០២១នេះ នឹងមានអត្រាកំណើន ៥,៨% ដែលខ្ពស់ជាងការព្យាករណ៍ កាលពីខែធ្នូ ឆ្នាំ២០២០ ក្នុងអត្រាកំណើន ៤,២%។ បន្ថែមពីនេះទៀត កំណើនសេដ្ឋកិច្ច ឆ្នាំ២០២២ ត្រូវបានព្យាករណ៍ថា នឹងមានអត្រា ៤,៤% ដែលនេះបង្ហាញថា សេដ្ឋកិច្ច

ប្រទេសភាគច្រើនលើពិភពលោក បានវិលត្រលប់ទៅរកទំហំមុនវិបត្តិជំងឺកូវីដ-១៩។ ទោះបីជាយ៉ាងណាក៏ដោយ ការងើបឡើងវិញនេះ មិនមានភាពស្មើគ្នាទេ ហើយស្តង់ដារជីវភាពរស់នៅរបស់ប្រជាជននៃប្រទេសអភិវឌ្ឍន៍ជាច្រើន នៅតែមិនទាន់អាចសម្រេចបាននូវកម្រិតរំពឹងទុក មុនវិបត្តិរាតត្បាតនោះឡើយ។

ទិន្នផលសេដ្ឋកិច្ចសហរដ្ឋអាមេរិក ចិន និងអាល្លឺម៉ង់ នៅចុងឆ្នាំ២០២២នឹងមានកម្រិតខ្ពស់ជាងការព្យាករណ៍កាលពីវិច្ឆិកា ឆ្នាំ២០១៩ទៅទៀត។ ដោយឡែក ចំពោះទិន្នផលសេដ្ឋកិច្ចប្រទេសជាច្រើន នៅអឺរ៉ុបវិញ ជាពិសេសប្រទេសដែលពឹងផ្អែកលើវិស័យទេសចរណ៍ នឹងមានកម្រិតទាបជាងមុនពេលមានវិបត្តិ ហើយគម្លាតនេះមានទំហំកាន់តែធំ ចំពោះប្រទេសមានទីផ្សារកំពុងងើបឡើង។ ជាក់ស្តែង ទិន្នផលសេដ្ឋកិច្ចឥណ្ឌា មានកម្រិតទាបជាងការព្យាករណ៍កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ប្រមាណ ១០%។

ទន្ទឹមនេះដែរ ប្រធានសេដ្ឋកិច្ចនៃ OECD លោកស្រី Laurence Boone បានលើកឡើងថា ថ្វីបើប្រទេសលើពិភពលោក បានធ្វើដំណើរឆ្ពោះទៅរកទស្សនវិស័យល្អប្រសើរក៏ដោយ ក៏ប៉ុន្តែ គ្រោះថ្នាក់នៅតែមាននៅពេលដែលរដ្ឋាភិបាលបានជឿជាក់ថា ខ្លួនបានធ្វើគ្រប់គ្រាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ច។

បន្ថែមពីនេះទៀត ការបរាជ័យក្នុងការផ្គត់ផ្គង់វ៉ាក់សាំងកូវីដ-១៩ ទៅដល់ប្រទេសមានទីផ្សារកំពុងងើបឡើង និងប្រទេសកំពុងអភិវឌ្ឍន៍ គឺជាហានិភ័យធំបំផុតចំពោះការព្យាករណ៍ OECD នេះ៕ *ដោយ ជា សិរីតន៍*

*ប្រភព៖ Financial Times, ចេញផ្សាយថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០២១*

## អតិផរណាអាមេរិក ត្រូវបានរំពឹងថា នឹងមានអត្រា ចន្លោះ ២,៥% ទៅ ៣% នៅឆ្នាំ២០២១នេះ



*ប្រភព៖ Talk Business & Politics ២០២១*

យោងតាមការសម្ភាសន៍របស់ CNBC ជាមួយនឹងប្រធានធនាគារសហព័ន្ធ St. Louis លោក Bullard បង្ហាញថា អតិផរណាឆ្នាំនេះ ត្រូវបានរំពឹងថា នឹងមានអត្រាខ្ពស់នៅចន្លោះ ២,៥% ទៅ៣% រីឯ ឆ្នាំ២០២២ លោករំពឹងថា អតិផរណា នឹងមានអត្រា ២,៥%។

ក្នុងនោះដែរ លោកបានលើកឡើងថា អត្រាអតិផរណាខ្ពស់នេះ អាចជាផ្នែកមួយនៃយុទ្ធសាស្ត្រធនាគារសហព័ន្ធក្នុងការព្យាយាមប៉ះប៉ូវឡើងវិញ លើការខកខានក្នុងការអនុវត្តអតិផរណាគោល ២%របស់ខ្លួន។ លោកបានបន្តថា អតិផរណា បានធ្លាក់ចុះទៅទាបជាអត្រាគោលដៅនៅទស្សវត្សរ៍ចុងក្រោយនេះ ហើយធនាគារសហព័ន្ធមានបំណងចង់ពង្រឹងអត្រាអតិផរណាគោលនេះឡើងវិញ៕ *ដោយ ជា សិរីតន៍*

*ប្រភព៖ Talk Business & Politics, ចេញផ្សាយថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៧ ខែមិថុនា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ចិន ក្នុងខែមេសាឆ្នាំ ២០២១
- កំណើនផលិតកម្មឧស្សាហកម្មរបស់អេស្ប៉ាញ ក្នុងខែមីនាឆ្នាំ ២០២១។

ថ្ងៃអង្គារ៍ ទី០៨ ខែមិថុនា ឆ្នាំ២០២១

- កំណើនអតិរេកគណនីចរន្តរបស់កូរ៉េខាងត្បូង នាខែកុម្ភៈឆ្នាំ ២០២១
- ការធ្លាក់ចុះសេដ្ឋកិច្ចជប៉ុន ក្នុងត្រីមាសទី ១ ក្នុងឆ្នាំ ២០២១។

ថ្ងៃពុធ ទី០៩ ខែមិថុនា ឆ្នាំ២០២១

- កំណើនអត្រាអតិផរណាប្រចាំឆ្នាំរបស់ចិនក្នុង ខែមេសាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មនៅប្រទេសអាល្លឺម៉ង់ នៅ ខែមីនាឆ្នាំ ២០២១។

ថ្ងៃព្រហស្បតិ៍ ទី១០ ខែមិថុនា ឆ្នាំ២០២១

- អត្រាអតិផរណានៅអូស្ត្រាលី បានកើនឡើងដ នៅក្នុងខែឧសភា ឆ្នាំ ២០២១
- កំណើនផលិតកម្មឧស្សាហកម្មនៅក្នុងប្រទេស អ៊ីតាលី នៅខែមីនាឆ្នាំ ២០២១។

ថ្ងៃសុក្រ ទី១១ ខែមិថុនា ឆ្នាំ២០២១

- សហរដ្ឋអាមេរិកបានបង្ហាញឱនភាពថវិកាក្នុង ខែមេសាឆ្នាំ ២០២១
- ឱនភាពពាណិជ្ជកម្មអង់គ្លេស បានកើនឡើង ក្នុងខែមីនាឆ្នាំ ២០២១។